**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤៣.សសរ

# សេចក្ដីសំរេច

**ស្ដីពី**

**ការបង្កើតគណៈកម្មការ ដើម្បីពិនិត្យ**

**វាយតម្លៃឡូត៍នេសាទសិក្សាស្រាវជ្រាវ**

* * *

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញក្រឹត្យច្បាប់លេខ ៣៣ ក្រ ចុះថ្ងៃទី ០៩ ខែ មិនា ឆ្នាំ ១៩៨៧ ស្ដីពីការគ្រប់គ្រងវិស័យជលផល
- យោងតាមការងារចាំបាច់

**សំរេច**

**ប្រការ ១** : បង្កើតគណៈកម្មការមួយ ដើម្បីពិនិត្យវាយតម្លៃឡូត៍នេសាទសិក្សាស្រាវជ្រាវដែលមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១-ឯកឧត្ដម **ច័ន្ទ សុខអ៊ីម** | រដ្ឋមន្ត្រីស្ដីទី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រធាន |
| ២-ឯកឧត្ដម **អ៊ុក រ៉ាប៊ុន** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣-ឯកឧត្ដម **ច័ន្ទ សារុន** | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៤-ឯកឧត្ដម **ម៉ុន ស៊ីយ** | អនុរដ្ឋលេខាធិការ ទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |

www.pheakdeylaw.com

៥-ឯកឧត្តមអភិបាលខេត្ត-ក្រុង ដែលមានឡូត៍នេសាទ សមាជិក

៦-លោក ណៅ ធួក ប្រធាននាយកដ្ឋានជលផល សមាជិក

៧-លោក ភាំង ឃាងខំណា ប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៨-លោក ញ៉ិប ចន់ថេត ប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក

៩-លោក អេង ជាសន អនុប្រធាននាយកដ្ឋានជលផល លេខាធិការ

**ប្រការ ២** : គណៈកម្មការនេះ មានភារកិច្ចដូចតទៅ ៖

_ចុះពិនិត្យវាយតម្លៃតាមសភាពការណ៍ជាក់ស្តែងលើឡូត៍នេសាទសិក្សាស្រាវជ្រាវដែលនៅសេសសល់ ។

_ពិភាក្សាលើកយោបល់អំពីទិដ្ឋភាពច្បាប់ ទិដ្ឋភាពបច្ចេកទេស ទិដ្ឋភាពសេដ្ឋកិច្ច និង សង្គម ។

_រាយការណ៍អំពីលទ្ធផលការងារ និង លើកអំពីវិធានការដោះស្រាយជូនរាជរដ្ឋាភិបាលពិនិត្យ និងសំរេច ដើម្បីអោយការងារធ្វើអាជីវកម្មនេសាទ បានទាន់រដូវនេសាទឆ្នាំ ២០០១ ។

**ប្រការ ៣** : គណៈកម្មការនេះ អាចបង្កើតអនុគណៈកម្មការជាជំនួយការតាមការចាំបាច់ ហើយមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

**ប្រការ ៤** : សមាជិកគណៈកម្មការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ៥** : គណៈកម្មការនេះត្រូវរំសាយជាស្វ័យប្រវត្តិ នៅពេលដែលបានបំពេញភារកិច្ចចប់ជាស្ថាពរ ។

**ប្រការ ៦** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អភិបាលខេត្ត_ក្រុង ពាក់ព័ន្ធ និង ឯកឧត្តម អស់លោកដែលមានចែងក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០១*

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៦*
- *ឯកសារ_កាលប្បវត្តិ*